**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**តុលាការកំពូល**
សំណុំរឿង រដ្ឋប្បវេណី
លេខៈ២៨៨
ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ២០០១
**សាលដីកា**
លេខៈ៥៧
ចុះថ្ងៃទី១៤ ខែមីនា ឆ្នាំ២០០២

**តាងនាមប្រជារាស្ត្រខ្មែរ**
**តុលាការកំពូល**

បានបើកសវនាការជំនុំជំរះជាសាធារណៈ នៅថ្ងៃទី១៤ ខែមីនា ឆ្នាំ២០០២ ដោយមានសមាសភាពដូចតទៅៈ

១-ឯកឧត្តម .......... ជាប្រធាន
២-លោក ............. ជាចៅក្រម
៣-លោក ............ ជាចៅក្រម
៤-លោក ............ ជាចៅក្រម
៥-លោក ............. ជាចៅក្រមរបាយការណ៍

**ក្រឡាបញ្ជី**

-លោក ................

**តំណាងមហាអយ្យការ**

-លោក ................... ជាព្រះរាជអាជ្ញា

ដើម្បីជំនុំជំរះ លើបណ្តឹងសាទុក្ខពីសាលដីកាលេខ៨៦(ឈ) ចុះថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០០១ នៃសំណុំរឿងរដ្ឋប្បវេណីលេខ៣៥៨ ចុះថ្ងៃទី១៦ ខែឧសភាឆ្នាំ២០០១ របស់សាលាឧទ្ធរណ៍ ។

រវាងដើមចោទឈ្មោះ ហគ(ចុងបណ្តឹងសាទុក្ខ) ភេទប្រុសអាយុ៥២ឆ្នាំ ជាតិខ្មែរ មុខរបរ លក់ដូរ ទីលំនៅផ្ទះគ្មានលេខផ្លូវ ហាវ៉ េ សង្កាត់ស្ទឹងមានជ័យ ខណ្ឌមានជ័យ ក្រុងភ្នំពេញ។ឪពុកឈ្មោះវេង យុន (ស) ម្តាយឈ្មោះ សៀម អេង(ស) ប្រពន្ធឈ្មោះលឹម មុំ ។

- និងក្នុងចម្លើយឈ្មោះ ធ(ដើមបណ្តឹងសាទុក្ខ) ភេទប្រុស អាយុ៣២ឆ្នាំ ជាតិតៃវ៉ាន់ មុខរបរ ពាណិជ្ជករ ទីលំនៅផ្ទះ២៥៤Eo ផ្លូវលេខ១៤៣ សង្កាត់បឹងកេងកងទី៣ ខណ្ឌចំការមន រាជធានី ភ្នំពេញ ។ ខ្ញុំពុកឈ្មោះ ហ្វាង ចុងអ៊ី(រ) ម្តាយឈ្មោះឆិម ពី(រ) ប្រពន្ធឈ្មោះឌី ហួយ ។

មានមេធាវី អ្នកស្រី ..........

-តតីយជក្រុមហ៊ុន Grand Power Concret Enterprise តំណាងដោយឈ្មោះវេជជផ្ទេរសិទ្ធិឱ្យមេធាវី .............. ។

- អំពីវិវាទ ប្តឹងសុំឱ្យអនុវត្ត និងគោរពតាមកិច្ចសន្យាទិញលក់ដី ។

បានឃើញបណ្តឹងសាទុក្ខលេខ៦៨២ ចុះថ្ងៃទី១៧ ខែសីហាឆ្នាំ២០០១ របស់លោកពជរតំណាង ឱ្យចុងចម្លើយ ប្តឹងមិនសុខចិត្តពីសាលដីការដ្ឋប្បវេណីលេខ៨៦(ឈ) ចុះថ្ងៃទី២៦ ខែមិថុនា ឆ្នាំ ២០០០១ របស់សាលាឧទ្ធរណ៍ លើសេចក្តីវិនិច្ឆ័យទាំងមូល ។

បានឃើញសំណុំរឿងរដ្ឋប្បវេណីល២៨៨ចុះថ្ងៃទី២៤ខែតុលា ឆ្នាំ២០០១ របស់តុលាការកំពូល ។

តាមពាក្យបណ្តឹង ចុះថ្ងៃទី២៧-១១-២០០០ របស់ឈ្មោះហគ ប្តឹងសុំឱ្យអនុវត្ត និងគោរពតាមកិច្ចសន្យាទិញលក់ដីពីឈ្មោះធ ដោយសំអាងហេតុថាខ្លួន និងប្រុមហ៊ុនGrand Power Concret Enterprise បានទិញដីហើយ មិនបានប្រគល់ប្រាក់ឱ្យមកខ្លួនគ្រប់ចំនួន ។

តាមពាក្យបណ្តឹងសុំចូលជាតតិយជនរបស់មេធអ៊ី ..................... តំណាងក្រុមហ៊ុន Grand Power Concret Enterprise ដោយហេតុថា ការទិញលក់ដី គឺហគ បានលក់ឲ្យក្រុមហ៊ុនឈ្មោះធ គ្រាន់តែជាតំណាងក្នុងការទិញលក់ប៉ុណ្ណោះ និងសុំឱ្យបដិសេធដីកាសម្រេកិច្ចការប្រញាប់លេខ១៦ ប្រខ ចុះថ្ងៃទី ០៦-១២-២០០០ ។

បានឃើញ សាលក្រមរដ្ឋប្បវេណីលេខ១៦(ខ) ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០១ របស់តុលាការក្រុងភ្នំពេញ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅៈ

១-ទទួលពាក្យបណ្តឹងរបស់ដើមចោទឈ្មោះហគ ចុះថ្ងៃទី២៧-១១-២០០០ ទុកជាត្រឹត្រូវតាមទម្រង់ និងគតិច្បាប់ ។

២-ទទួលថាការផ្ទេរសិទ្ធិពីក្រុមហ៊ុន Grand Power Concret Enterprise មកឱ្យមេធាវី ............ ចុះថ្ងៃទី១៩-១២-២០០០ ចូលជាតំណាង និងអ្នកការពារ ជាត្រឹមត្រូវតាមទម្រង់ និងគតិច្បាប់ ។

៣- ទទួលថា ពាក្យសុំថណាយក្តីចុះថ្ងៃទី២៥-១២-២០០០ របស់មេធាវី.................ជាអ្នកការពារក្តីឱ្យ ធ ទុកជាត្រឹមត្រូវតាមច្បាប់ ។

៤- ទទួលពាក្យបណ្តឹងចូលជាតតិយជន ចុះថ្ងៃទី២១-១២-២០០០ របស់មេធាវី ............ ទុកជាត្រឹមត្រូវតាមទម្រង់ និងគតិច្បាប់ ។

៥-បង្គាប់ឲ្យឈ្មោះហគ និងក្រុមហ៊ុន Grand Power Concret Enterprise អនុវត្តកិច្ចព្រមព្រៀងរបស់ខ្លួន គឺក្រុមហ៊ុនត្រូវបង់ចំនួន២៤០០០ដុល្លា(ពីរម៉ឺនបួនពាន់ដុល្លាអាមេរិក) ជារៀងរាល់ខែរហូតដល់គ្រប់ចំនួន២៨០០០០ដុល្លា (ម្ភៃប្រាំបីម៉ឺនដុល្លាអាមេរិក) ឲ្យទៅឈ្មោះហគ

៦- បង្គាប់ឱ្យលុបឈ្មោះធ និងលហបេចេញពីវិញ្ញាបនប័ត្រសំគាល់ម្ចាស់អចលនវត្ថុលេខ ៩០២៤ ចុះថ្ងៃទី១៣-០៥-៩២ ហើយដាក់ជារបស់ក្រុមហ៊ុន Grand Power Concret Enterprise វិញ ។

៧-បង្គាប់ក្រុមហ៊ុន Grand Power Concret Enterprise បង់ប្រាក់ប្រដាប់ក្តីគឺៈ

-ពន្ធចុះបញ្ជីត្ត និងពន្ធហ្នឹង ១៨០០រៀល រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ ២០០រៀល រង្វាន់អ្នកប្រគល់ដីកាកោះ៣០០០រៀល រង្វាន់សាក្សី២០០០រៀល ប្រាក់នេះបានកត់យកពីប្រាក់៧០០០រៀល

ដែលដើមចោទ បានបង់ទុករួចហើយ កាលបើផុតបណ្តឹងឧទ្ធរណ៍ បង្គាប់ឱ្យក្រុមហ៊ុននេះសងប្រាក់ ៧០០០រៀល ទៅដើម ចោទវិញ ហើយឱ្យបង់ពន្ធសមាមាត្រចំនួន១% លើទឹកប្រាក់ត្រូវសងចំនួន ២៨០០០០ (ម្ភៃប្រាំបីម៉ឺនដុល្លាអាមេរិក) ត្រូវជា២៨០០ដុល្លា (ពីរពាន់ប្រាំបីរយដុល្លាអាមេរិក) ប្រាក់នេះត្រូវបង់ចូលថវិការដ្ឋ៨០% និងបានជារង្វាន់ក្រឡាបញ្ជីទូទាំងប្រទេស២០% ។

៨-សាលក្រមនេះជំនុំជំរះ និងប្រកាសជាសាធារណៈ ចំពោះមុខគូក្តី និងតតិយជនខាងចុងចម្លើយ មេធាវីរបស់ចុងចម្លើយ និងមេធាវីរបស់តតិយជន បើកផ្លូវឧទ្ធរណ៍ក្នុងកំណត់ច្បាប់ ។

បានឃើញ បណ្តឹងឧទ្ធរណ៍លេខ០៩(ខ) ចុះថ្ងៃទី០៩ ខែមេសា ឆ្នាំ២០០១ របស់ឈ្មោះធ ប្តឹងមិនសុខចិត្ត និងសាលក្រមលេខ១៦(ខ) ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០១ របស់តុលាការក្រុងភ្នំពេញ លើសេចក្តីសម្រេចទាំងមូល នៃសាលក្រម ។

បានឃើញ សាលដីការដ្ឋប្បវេណីលេខ៨៦(ឈ) ចុះថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០០១ របស់សាលាឧទ្ធរណ៍ ដែលមានខ្លឹមសារ នៃសេចក្តីសម្រេចដូចតទៅៈ

១- ទទួលពាក្យបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី០៩-០៤-២០០១ របស់ឈ្មោះធ ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោល ដោយទាស់នឹងគតិច្បាប់ ។

២- តម្កល់សាលក្រមរដ្ឋប្បវេណីលេខ១៦(ខ) ចុះថ្ងៃទី១៥-០២-២០០១ របស់តុលាការ ក្រុងភ្នំពេញ ទុកជាបានការដដែល ។

៣- ទុកសិទ្ធិឱ្យឈ្មោះធ ជាចុងចម្លើយប្តឹងទាមទារប្រាក់ចំនួន៦០០០០ដុល្លាអាមេរិក (ប្រាំមួយម៉ឺនដុល្លាអាមេរិក)ពីក្រុមហ៊ុន Grand Power Concret Enterprise នៅតុលាការ ថ្នាក់ព្រៃម ។

៤- កាត់យកប្រាក់ប្រដាប់ក្តី ជាន់សាលាឧទ្ធរណ៍ចំនួន១៣០០០រៀល ដែលដើមចោទបានបង់ទុករួចហើយគឺពន្ធចុះបញ្ជីក្តី និងពន្ធហ៊ឹងចំនួន២៥០រៀល រង្វាន់ រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ចំនួន៤៥០រៀល ចំណាយលើការប្រគល់ដីកាកោះចំនួន៥០០០រៀល និងអាជ្ញាធរតុលាការចំនួន៥.០០០រៀល។ នៅពេលសាលដីកានេះចូលជាស្ថាពរ បង្គាប់ឱ្យចុងចម្លើយបង់សងទៅដើមចោទវិញ ។

៥- សាលដីកានេះ ជំនុំជំរះ និងប្រកាសជាសាធារណៈ ចំពោះមុខដើមចោទ មេធាវីតំណាង ចុងចម្លើយ កំបាំងមុខតតិយជន តែចាត់ទុកជាចំពោះមុខ ។

បើកផ្លូវប្តឹងសាទុក្ខក្នុងកំណត់ច្បាប់ ។

បានឃើញ បណ្តឹងសាទុក្ខលេខ២៨២ ចុះថ្ងៃទី១៧ ខែសីហា ឆ្នាំ២០០១ របស់លោកពធរ មេធាវីតំណាងឱ្យចុងចម្លើយ ប្តឹងមិនសុខចិត្តនឹងសាលដីការដ្ឋប្បវេណីលេខ៨៦(ឈ) ចុះថ្ងៃទី២៦ខែ មិថុនា ឆ្នាំ២០០១ របស់សាលាឧទ្ធរណ៍ លើត្រង់ចំណុចសេចក្តីវិនិច្ឆ័យទាំងមូល ។

បានស្តាប់របាយការណ៍ របស់ចៅក្រមរបាយការណ៍

បានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការថាៈបណ្តឹងសាទុក្ខរបស់ចុងចម្លើយធ្វើឡើង ស្ថិតក្នុងកំណត់ច្បាប់ គប្បីលើកយកមកពិចារណា។

សាលដីការដ្ឋប្បវេណីលេខ៨៦(ឈ) ចុះថ្ងៃទី២៦-០៦-២០០១ របស់សាលាឧទ្ធរណ៍ ដែលបានសម្រេចសេចក្តីមកនេះ មានលក្ខណៈត្រឹមត្រូវតាមទម្រង់ និងគតិច្បាប់ហើយ ។

សូមក្រុមប្រឹក្សាជំនុំជំរះមេត្តាពិចារណាតាមច្បាប់តទៅ

បានស្តាប់ចម្លើយរបស់ឈ្មោះហគ ឆ្លើយថា ខ្លួននៅតែសុំរក្សាឱ្យគោរពតាមកិច្ចសន្យាទិញ-លក់ ដីដូចមានក្នុងកម្មវត្ថុបណ្តឹងដដែល ។

បានស្តាប់សេចក្តីសន្និដ្ឋានរបស់លោកម៉ៅ សំរិទ្ធារី ជាមេធាវី តំណាងក្រុមហ៊ុនGrand Power Concret Enterprise បញ្ជាក់ថាៈក្នុងនាមខ្ញុំ ជាតំណាងឲ្យក្រុម គឺ នៅតែសុំឲ្យគោរពតាមកិច្ចសន្យាលក់-ទិញ-លក់ដី ដូចមានក្នុងកម្មវត្ថុបណ្តឹងដដែល ។ ចំពោះលុយ ៦ម៉ឺនដុល្លាអាមេរិកឈ្មោះធ បានប្តឹងទៅតុលាការរួចហើយ ។

-ក្រោយពីបានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យករ

-ក្រោយពីបានស្តាប់ចម្លើយរបស់ដើមចោទ និងសេចក្តីសន្និដ្ឋានរបស់មេធាវីតតិយជន.

## តុលាការកំពូល

– យល់ឃើញថា បណ្តឹងសាទុក្ខលេខ៦៨២ ចុះថ្ងៃទី១៧ ខែសីហា ឆ្នាំ ២០០០ របស់លោកធ ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូល អាចលើករឿងនេះមកជំនុំជំរះ បានតាមមាត្រា១៤ នៃច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពរបស់សាលាជំរះក្តី ។

-យល់ឃើញថា តាមកិច្ចសន្យាលក់-ទិញអចលនវត្ថុ ចុះថ្ងៃទី០៥-០៥-២០០០ រវាងដើមចោទលោក ហគ និង ប្រពន្ធអ្នកស្រី លីម មុំម ជាភាគី (ក) និងចុងចម្លើយឈ្មោះធ(Grand Power Concret Enterprise) ជាភាគី(ខ) ពិតជាបានទិញដីពីភាគីដើមចោទក្នុងតម្លៃ៦០០០USD ពិតប្រាកដមែន ហើយដែលដើមចោទ ក៏បានអះអាងថា ខ្លួនបានលក់ដីឱ្យទៅក្រុមហ៊ុនហ្គ្រែន ផាវ័រ ខុនគ្រីត អ៊ុនធឺប្រាយ គឺពុំមែនលក់ទៅឱ្យបុគ្គលធទេ.

- យល់ឃើញថា តាមលិខិតឯកភាពផ្ទេរសិទ្ធិអចលនវត្ថុ ចុះថ្ងៃទី ០៩-០៧-២០០០ និងកិច្ចសន្យា ចុះថ្ងៃទី១៤-០៨-២០០០ ឈ្មោះធ និងប្រពន្ធ បានព្រមព្រៀងផ្ទេរសិទ្ធិកាន់កាប់ដីដែលមានវិញ្ញាបនបត្រសំគាល់ម្ចាស់អចលនវត្ថុលេខ៩០២៤ ចុះថ្ងៃទី១៣-០៥-៩២ មកឲ្យក្រុមហ្គ្រែន ផាវ័រ ខុនគ្រីត អ៊ិនធឺប្រាយ វិញហើយនេះបញ្ជាក់ឱ្យឃើញថា ឈ្មោះធ ទទួលស្គាល់ ថាខ្លួនពិតជាតំណាងក្នុងការឈរឈ្មោះទិញដីពីដើមចោទ ឱ្យតតិយជន ដែលជាក្រុមហ៊ុនហ្គ្រែន ផាវ័រ ខុនគ្រីត អ៊ិនធឺប្រាយ ពិតប្រាកដមែន ។

- យល់ឃើញថាលោកធ បានដាក់ពាក្យបណ្ដឹង ចុះថ្ងៃទី២៧-១០-២០០០ ទៅតុលាការក្រុងភ្នំពេញទាមទារប្រាក់ពីក្រុមហ៊ុន ហ្គ្រែន ផាវ័រ ខុនគ្រីត អ៊ិនធឺប្រាយ តាមកិច្ចសន្យា ចុះថ្ងៃទី១៤-០៨-២០០០ រួចហើយ ។

- យល់ឃើញថា តតិយជនជាក្រុមហ៊ុនហ្គ្រែន ផាវ័រ ខុនគ្រីត អ៊ិនធឺប្រាយ បានប្រគល់ ប្រាក់ថ្លៃទិញដី មួយចំនួនឱ្យទៅដើមចោទរួចហើយ ហើយប្រាក់ដែលនៅសល់ពុំទាន់សងនោះ ដើមចោទ និងក្រុមហ៊ុនជានឯកភាពគ្នា ក្នុងការទូរទាត់បន្តហើយដែរ ។

-យល់ឃើញថា តតិយជនពុំបានមកចូលរួមនាសវនាការនេះទេ ប៉ុន្តែមេធាវី របស់តតិយជន បានមកចូលរួមហើយ ដូច្នេះ តុលាការកំពូល ជំនុំជំរះកំបាំងមុខ ចាត់ទុកជាចំពោះមុខ ។

-យល់ឃើញថា មេធាវីរបស់លោកធ បានទទួលលិខិតបង្គាប់ឱ្យធ្វើសារណារួមហើយ ហើយក៏បានសុំពន្យាពេល១០ថ្ងៃផែមទៀត ប៉ុន្តែលោកធ នៅតែពុំបានជូនសារណារបស់ខ្លួន មកតុលាការកំពូលទេ ហើយពុំបានកចូលរួមនាសវនាការនេះដែរ ដូច្នេះតុលាការកំពូល ជំនុំជំរះកំបាំងមុខ ចាត់ទុកជាចំពោះមុខ ។

- យល់ឃើញថា សាលដីការដ្ឋប្បវេណីលេខ៨៦(ឈ) ចុះថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០០១ របស់សាលាដុទ្ធរណ៍ ដែលបានសម្រេចសេចក្ដីមកនេះ មានលក្ខណៈត្រឹមត្រូវ តាមទម្រង់និងគតិច្បាប់ហើយ ។

**ហេតុដូច្នេះ**

**សម្រេចសេចក្ដីចំពោះមុខដើមចោទ កំបាំងមុខចុងចម្លើយ និងតតិយជន ប៉ុន្តែចាត់ទុកជាចំពោះមុខ**

១-ទទួលបណ្ដឹងសាទុក្ខលេខ២៨២ ចុះថ្ងៃទី១៧-០៨-២០០១ របស់លោកធ ធ្វើឡើងត្រឹមត្រូវតាមទម្រង់ច្បាប់ ប៉ុន្តែបដិសេធចោល ដោយខុសនឹងគតិច្បាប់ ។

២- តម្កល់សាលដីការដ្ឋប្បវេណីលេខ៨៦(ឈ) ចុះថ្ងៃទី២៦-០៦-២០០១ របស់សាលាឧទ្ធរណ៍ទុកជាបានការពេញទំងមូល ។

៣- រឹបអូសប្រាក់ប្រដាប់ក្ដី ដែលដើមចោទ បានបង់រួចហើយ នៅតុលាការកំពូល ចំនួន ១៩០០០ រៀល គឺ:

-ពន្ធចុះបញ្ជីក្ដី និងពន្ធហ្នឹងចំនួន៤០០០រៀល ប៉ុន្តែប្រាក់នេះត្រូវកាត់ចំនួន៨០០ រៀល សម្រាប់ជារង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់

-ចំណាយលើកកិច្ចប្រគល់ដីការកោះ១៥០០០រៀល សរុបចំនួន១៩០០០រៀល ហើយតម្រូវឱ្យក្រុមហ៊ុនហ្គ្រែន ផាវ័រ ខុនគ្រីត អ៊ិនធឺប្រាយ សងប្រាក់ចំនួន១៩០០០រៀល ទៅលោកហគ វិញ និងបង្គាប់ឲ្យក្រុមហ៊ុន Grand Power Concret Enterprise បង់ពន្ធសមាមាត្រ តាមការកំណត់ របស់តុសាការក្រុងភ្នំពេញ ។

៤- សាលដីកានេះ ប្រកាសនាសវនាការជាសាធារណៈ នៅថ្ងៃទី១៤ខែមីនា ឆ្នាំ២០០២ ។,